៤ 10-6-2016
RIN

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
៩៤០/១៩-១០-២០១១
សាលដីកា
លេខ: ៣៦ "ក្រ.ប.ស"
ចុះថ្ងៃទី ២០-០៤-២០១២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ០៥-០៤-២០១២ ដែលមានសមាសភាពដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៩៤០ ចុះថ្ងៃទី ១៩-១០-២០១១ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] គឹមសេង ភេទប្រុស អាយុ ៦៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកកំពង់សៀម ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ [redacted] មានកូន ០៧នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន (ក្រៅឃុំ) ។

២-ជនជាប់ចោទឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកពញាក្រែក ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៣-ជនជាប់ចោទឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted] ស្រុកពញាក្រែក ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន (ក្រៅឃុំ) ។

៤-ជនជាប់ចោទឈ្មោះ [redacted] រ៉ាវី ភេទប្រុស អាយុ ១៨ឆ្នាំ មានទីលំនៅភូមិ [redacted] ពញាក្រែក ខេត្តកំពង់ចាម (ឃុំខ្លួន)។

ជាប់ចោទពីបទៈ ប្លន់ទ្រព្យសម្បត្តិ ប្រព្រឹត្តនៅភូមិជីមានកណ្តាល ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៩-០៤-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហេង ភេទស្រី អាយុ ៥២ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិជីមាន់កណ្តាល ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម ។

## ៦រឿងហេតុមានដូចតទៅ

**សង្ខេបអង្គហេតុ** ប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ ៖

កាលពីថ្ងៃទី ១៦-៧-២០០៥ វេលាម៉ោង ១៦ និង ៣០នាទី នៅផ្ទះជនរងគ្រោះឈ្មោះ [redacted] ហេង ត្រូវគេគាស់ទ្វារយកទ្រព្យសម្បត្តិដូចជាប្រាក់ខ្មែរចំនួន ៧៨ម៉ឺនរៀល ប្រាក់ដុល្លា ៥០០ ដុល្លា ខ្សែដៃមាសទម្ងន់ ១០ជី និងចិញ្ចៀន ០១ជី។ ជនរងគ្រោះសង្ស័យទៅលើឈ្មោះ [redacted] ស្រីពៅ ព្រោះជញ្ជាំងផ្ទះជាប់គ្នា មានការគាស់ជញ្ជាំងផ្ទះ ០២ កន្លែង មានស្នាមជើងចុះពីលើជាន់លើពូក។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តកំពង់ចាម សម្រេចអំណាចសាល-ក្រមព្រហ្មទណ្ឌលេខៈ ៥១ "គ" ចុះថ្ងៃទី ២៣ -០៦-២០០៦ សម្រេចថាៈ

១-ផ្តន្ទាទោស ៖

-ឈ្មោះ [redacted] គឹមសេង ភេទប្រុស អាយុ ៦៣ឆ្នាំ ជាតិខ្មែរ

-ឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ

-ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ១៩ឆ្នាំ

-ឈ្មោះ [redacted] រ៉ាវី ភេទប្រុស អាយុ ១៨ឆ្នាំ

ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ១០ឆ្នាំ (ដប់ឆ្នាំ) គិតពីថ្ងៃសាលក្រមចូលជាស្ថាពរពីបទៈ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ប្រព្រឹត្តនៅភូមិជីមាន់កណ្តាល ឃុំក្រែក ស្រុកពញា-ក្រែក ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទល្មើសឧក្រិដ្ឋ។

២-បង្គាប់ឱ្យឈ្មោះទាំងអស់ខាងលើ រួមគ្នាសងជម្ងឺចិត្ត និងការបាត់បង់ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហេង ចំនួន ៥.០០០ $ (ប្រាំពាន់ដុល្លាអាមេរិក) នៅពេលសាលក្រមចូលជាស្ថាពរហើយបើឈ្មោះទាំងអស់ ខាងលើមិនព្រមសងទេ នោះតុលាការនឹងរឹបអូសទ្រព្យសម្បត្តិចលនវត្ថុ និងអចលនវត្ថុ លក់ឡាយឡុង ដើម្បីសងសំណងធនទណ្ឌតាមកំណត់ច្បាប់។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឹមហេង, ឈ្មោះ [redacted] ស្រីពៅ និងកំបាំងមុខ ជនជាប់ចោទឈ្មោះ [redacted] កុសល ឈ្មោះ [redacted] រ៉ាវី ។ បើកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**បានឃើញ**បណ្តឹងឧទ្ធរណ៍លេខ ៦៩ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] ហេង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៨៧ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៥

របស់តុលាការកំពង់ចាម ត្រង់ចំណុចទាំងមូលរបស់សាលក្រម ដោយមូលហេតុតុលាការខេត្តកំពង់ចាម បានកាត់សេចក្ដីឱ្យនាងខ្ញុំត្រូវហើយ តែឈ្មោះ [redacted] តឹមសេង និងកូនទាំងអស់ មិនព្រមទទួលស្គាល់កំហុស របស់ខ្លួនទៀត ដោយព្រមបង់លុយឱ្យមកនាងខ្ញុំ ដូច្នេះហើយទើបនាងខ្ញុំប្ដឹងសុំទាមទារសោហ៊ុយឡើងចុះ នឹងការខាតបង់ពេលវេលាប្រាក់ចំនួន ៥.០០០ ដុល្លា បន្ថែមលើប្រាក់សំណងនេះទៀត)។

**បានឃើញ**បណ្ដឹងឧទ្ធរណ៍លេខ ៦០ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] តឹមសេង, បណ្ដឹងឧទ្ធរណ៍លេខ ៦១ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] ស្រីពៅ នឹងបណ្ដឹងលេខ ៦៣ ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] វិណ្ណារិទ្ធ មេធាវីការពារឱ្យឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] រ៉ាវី ប្ដឹងមិនសុខចិត្តសាលក្រមព្រហ្មទណ្ឌលេខ ៣៨៧ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៥ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចសាលក្រមទាំងមូល

*រឿងក្ដីសាលាឧទ្ធរណ៍ សម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខៈ ៤៥ "ក" ចុះថ្ងៃទី ០៦-៤-២០០៩ ដែលមានខ្លឹមសារនៃសេចក្ដីដូចតទៅ ៖*

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] តឹមសេង និង [redacted] ស្រីពៅ និងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] កុសល ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] រ៉ាវី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

៣-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] មួយហេង ហៅមួយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់

៤-បដិសេធចោលចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខៈ ៥១ "គ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ របស់តុលាការកំពង់ចាម។

៥-ផ្ដន្ទាទោសឈ្មោះ [redacted] រ៉ាវី ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ពីបទៈ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៦-ឱ្យឈ្មោះ [redacted] ស្រីពៅ ឈ្មោះ [redacted] តឹមសេង និងឈ្មោះ [redacted] កុសល រួចផុតពីការចោទប្រកាន់ពីបទៈ ប្លន់ ។

៧-ចំណុចដ៏ទៃទៀតក្រៅពីចំណុចទី នៃសាលក្រមត្រូវរក្សាទុកនៅដដែល។

៨-សាលដីកានេះជំនុំជម្រះជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីពៅ, [redacted] សេង កំបាំងមុខឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] រ៉ាវី ។ បើកផ្លូវប្ដឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់ ។

**បានឃើញ**បណ្ដឹងទាស់លេខ ២០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រ៉ាវី ដែលប្ដឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ៤៥ "ក" ចុះថ្ងៃទី ០៦-៤-២០០៩ របស់សាលាឧទ្ធរណ៍លើសេចក្ដី សម្រេចទាំងមូល ។

*រឿងក្ដីសាលាឧទ្ធរណ៍ សម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខៈ ៦៦ "ឈ" ចុះថ្ងៃទី ០៤-១០-២០១០ ដែលមានខ្លឹមសារនៃសេចក្ដីដូចតទៅ ៖*

១-ទទួលបណ្ដឹងទាស់លេខៈ ២០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ភារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយផ្ទុយគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខៈ ៤៥ "ក" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១០ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ចាត់ទុកជាចំពោះ មុខកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងតវ៉ា តាមកំណត់ច្បាប់ ។

**បានឃើញ**បណ្ដឹងសាទុក្ខលេខ ១១១ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៩ របស់ឈ្មោះ [redacted] លឹម (ប្ដីរបស់ឈ្មោះ [redacted] ហេង ) ដែលប្ដឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ៤៥ (ក) ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

*រឿងក្ដីនេះតុលាការកំពូល សម្រេចតាមអំណាចសាលដីការព្រហ្មទណ្ឌលេខៈ ១៥៧ ចុះថ្ងៃទី ២៦-៨-២០១១ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចទៅ ៖*

១-ទទួលបណ្ដឹងសាទុក្ខលេខ ១១១ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៩ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លឹម និងបណ្ដឹងសាទុក្ខលេខ ១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ភ៉ារី ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៦ "ឈ" ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ទាំងមូល លើកលែងតែចំណុចទី ២ នៃសាលដីកានេះដែលទាក់ទិននឹង ៖

-ចំណុចទី៥ នៃសាលដីកាព្រហ្មទណ្ឌលេខ ៤៥ "ក" ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ត្រូវបដិសេធចោល ។

-ចំណុចទី៧ នៃសាលដីកាព្រហ្មទណ្ឌលេខ ៤៥ "ក" ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩ នេះទាក់ទិននឹងចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ ៥១ "គ" ចុះថ្ងៃទី ២៣-៦-២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ក៏ត្រូវបដិសេធចោលក៏ដែរ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១០ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ជំរៈជាថ្មី លើចំណុចទាំងពីរខាងលើនេះ។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ។

**-ការដែលតុលាការកំពូលសម្រេចសេចក្ដីនេះ ដោយយល់ឃើញថាៈ**

១-ការដែលសាលាឧទ្ធរណ៍សម្រេចប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] ភ៉ារី ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ៥ឆ្នាំនោះ ជាការភ័ន្តច្រលំ ពីព្រោះថា ជនជាប់ចោទឈ្មោះ [redacted] ភ៉ារី កើតនៅថ្ងៃទី ០៦-៤-១៩៨៨ ដូច្នេះបើគណនាអាយុដល់ថ្ងៃកើត ហេតុទី ០៩-៤-២០០៥ នោះឈ្មោះ [redacted] ភារី ទើបតែអាយុ ១៧ឆ្នាំ តែប៉ុណ្ណោះ។ ហេតុដូច្នេះ ឈ្មោះ [redacted] ភ៉ារី ស្ថិតនៅអនីតិជននៅឡើយ ដែលគប្បីសាលាឧទ្ធរណ៍ ពិចារណាអំពីកំរិតទណ្ឌកម្ម ក្នុងន័យជាអត្ថប្រយោជន៍របស់អនីតិជនដែលករណីនេះជាមូលហេតុនៃបណ្ដឹងសាទុក្ខ ស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ

២-ការដែលដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងសុំក្នុងសារណាការពាររបស់ខ្លួន ក៏ដូចនាពេលសវនាការ សុំឱ្យតុលាការកំពូលផ្ដន្ទាទោសលើជនជាប់ចោទទាំងអស់ ដែលសាលាឧទ្ធរណ៍ បានសម្រេចឱ្យរួចខ្លួននោះតុលាការកំពូលមិនពិចារណាបានទេ ព្រោះថាតាមស្មារតីមាត្រា ៣៧៥ និងមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌភាគីរដ្ឋប្បវេណីអាចតវ៉ា តែលើផលប្រយោជន៍រដ្ឋប្បវេណីតែប៉ុណ្ណោះ។

៣-ការដែលសាលាឧទ្ធរណ៍បានសម្រេចឱ្យជនជាប់ចោទសងសំណង ៥.០០០ ដុល្លាអាមេរិក ទៅដើមបណ្ដឹងរដ្ឋប្បវេណីនោះ សាលាឧទ្ធរណ៍មិនទាន់មានមូលដ្ឋានច្បាស់លាស់ នៅឡើយនោះទេ ពីព្រោះសាលាឧទ្ធរណ៍សម្រេចតាមតែការទាមទាររបស់ជនរងគ្រោះ គឺមិនបានវាយតម្លៃអំពើព្យសនកម្ម ដែលជនរងគ្រោះទទួលនោះទេ។ ម្យ៉ាងទៀត សាលាឧទ្ធរណ៍ សម្រេចឱ្យឈ្មោះ [redacted] ស្រីពៅ,ឈ្មោះ [redacted] គឹមហេង និងឈ្មោះ [redacted] កុសល រួចខ្លួនពីបទ ចោទតែចុះគឱ្យអ្នកទាំងបីទទួលខុសត្រូវសំណងរដ្ឋប្បវេណីដដែល ព្រោះបើអ្នកទាំងបីមិនបានប្រព្រឹត្តបទប្លន់នេះផង តើហេតុអ្វីក៏ឱ្យអ្នកទាំងបីទទួលខុសត្រូវលើសំណងជួសជុលការ ខូចខាតទៅកើត។

៤-សាលដីកាព្រហ្មទណ្ឌលេខ ៦៦ "ឈ" ចុះថ្ងៃទី ០៤-១០-២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះខុសខ្លះត្រូវខ្លះ ។

**បានឃើញ**របាយការណ៍រឿងព្រហ្មទណ្ឌលេខៈ៩៤០ ចុះថ្ងៃទី ១៩-១០-២០១១ របស់ចៅក្រមនៃសាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ២៧-០២-២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿងក្ដី ។

-ជនជាប់ចោទឈ្មោះ [redacted]រ៉ាវី (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហោង (អវត្តមាន)

-មេធាវីការពារជនជាប់ចោទលោក [redacted]ម៉ាច (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]រ៉ាវី ខ្ញុំកើតនៅថ្ងៃទី ០៦-០៤-១៩៨៨ ខ្ញុំបានចូលរួមគាត់ដែរ ហើយគេចខ្លួនទៅ ក្រោយមកគេចាប់ខ្ញុំ។ ពេលនោះខ្ញុំយកបានប្រាក់តែ ៧០០០០៛ ប៉ុណ្ណោះ មិនយកទ្រព្យសម្បត្តិទេ។ ខ្ញុំនៅក្មេងខ្វះការយល់ដឹង ពេលកើតហេតុខ្ញុំរៀនថ្នាក់ប្រហែលទី ៧ សុំដោះលែងរូបខ្ញុំ ដើម្បីបានសិក្សារៀនសូត្របន្តទៀត។

## សេចក្ដីសន្និដ្ឋានតំណាងមហាអយ្យការ

សូមក្រុមប្រឹក្សា សម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូលទៅលើអាយុជនជាប់ចោទ

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-មេធាវីលោក [redacted] ម៉ាច ធ្វើសេចក្ដីសន្និដ្ឋានថា: កូនក្ដីខ្ញុំ ពេលប្រព្រឹត្តបទល្មើសពេលនោះមាន អាយុ ១៧ឆ្នាំ ប៉ុណ្ណោះ ជាអនីតិជន សុំឱ្យព្យួរទោសកូនក្ដីខ្ញុំ ព្រោះមានការប៉ះពាល់ដល់អនាគតក្នុងការសិក្សារៀនសូត្រ សុំដោះលែងកូនក្ដីខ្ញុំ។

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្ដុតាងដែលពាក់ព័ន្ធនឹងរឿងក្ដី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍យល់ឃើញថា

១-សំណុំរឿងព្រហ្មទណ្ឌលេខ: ៩៤០ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១ ត្រូវបង្វិលមកពីតុលាការកំពូល តាមសាលដីកាលេខ ១៥៧ ចុះថ្ងៃទី ២៦-៨-២០១១ ដើម្បីឱ្យជំនុំជម្រះជាថ្មី យោងតាមមាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ។

២-កាលពីថ្ងៃទី ១៦-៧-២០០៥ ម៉ោងប្រហែល ៤ និង ៣០នាទី ឈ្មោះ [redacted] រ៉ាវី ដែលរស់នៅជាប់ជញ្ជាំងផ្ទះរបស់ដើមបណ្ដឹងឈ្មោះ [redacted] ហេង បានគាស់ជញ្ជាំងផ្ទះដែលជាប់គ្នា ហើយចូលទៅយកទ្រព្យរបស់ដើមបណ្ដឹង។ តាមការបញ្ជាក់របស់ដើមបណ្ដឹងថាទ្រព្យដែល បាត់បង់មានចំនួន ៥០០ $ ប្រាក់រៀល ៧៥ ម៉ឺនរៀល ខ្សែដៃមាស ទំងន់ ១០ជី ជញ្ជៀនមាស ១វង់ ចំនួន ១ជី។ នាពេលសវនាការជនជាប់ចោទ បានឆ្លើយសារភាពថា ពិតជាបានគាស់ជញ្ជាំងផ្ទះទៅលួចទ្រព្យរបស់ដើមបណ្ដឹងពិតមែន តែយកបានប្រាក់ចំនួន ៧០០០$ ទេ ក្រៅពីនោះមិនបានលួចយកឡើយ ហើយសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន។

៣-ជនជាប់ចោទឈ្មោះ [redacted] រ៉ាវី តាមសំបុត្រកំណើតលេខ ១៥២ ចុះថ្ងៃទី ០៨-១១-២០០៨ គិតមកដល់ថ្ងៃកើតហេតុថ្ងៃទី ០៩-៤-២០០៥ ជនជាប់ចោទមានអាយុ ទើបតែ ១៧ឆ្នាំ ទេ ដូច្នេះជនជាប់ចោទស្ថិតក្នុងវ័យអនីតិជន តុលាការនឹងពិចារណា ដល់អនីតិភាពរបស់ ជនជាប់ចោទ។

៤-ឈ្មោះ [redacted] ស្រីពៅ ឈ្មោះ [redacted] គឹមហេង និងឈ្មោះ [redacted] កុសល ត្រូវបានរួចផុតពីការចោទប្រកាន់ ដូច្នេះមិនត្រូវទទួលខុសត្រូវផ្នែកសំណងរដ្ឋប្បវេណីទេ ជនជាប់ចោទមាន តែឈ្មោះ [redacted] រាវី ម្នាក់ទេ ហើយជាអនីតិជន ដូច្នេះអាណាព្យាបាលត្រូវទទួលខុសត្រូវផ្នែកព្យសនកម្ម របស់ដើមបណ្ដឹង ដែលបាត់បង់។

៥-តាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌដែលអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង រឺធ្ងន់ជាង ហើយអង្គហេតុនេះ ត្រូវបានចោទប្រកាន់តាមមាត្រា ៧ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសគប្បីកែប្រែមកចោទប្រកាន់តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌវិញ។

៦-សាលដីកាសាលាឧទ្ធរណ៍លេខ: ៦៦ "ឈ" ចុះថ្ងៃទី ០៤-១០-២០១០ បានលើកយកសំអាងហេតុមកបញ្ជាក់មាន លក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ លើកលែងតែសេចក្ដីសម្រេចលើ

ចំណុចទី៥ នៃសាលដីកាលេខៈ ៤៥ "ក" ចុះថ្ងៃទី ០៦-៤-២០០៩ និងចំណុចទី ៧ ដែលទាក់ទងចំណុចទី២ នៃសាលក្រមលេខៈ ៥១ "គ" ចុះថ្ងៃទី ២៣-៦-២០០៦ ត្រូវបានតុលាការកំពូលបដិសេធចោល ដូច្នេះត្រូវសម្រេចជាថ្មី។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៩៤០ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៥៧ ចុះថ្ងៃទី ២៦-៨-២០១១ របស់តុលាការកំពូល។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រ៉ាវី ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ ពីបទ លួច មានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សាគាស់ទំលុះទំលាយ តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យអាណាព្យាបាលរបស់ឈ្មោះ [redacted] រ៉ាវី សងសំណងអន្តរាយ ទៅដើមបណ្តឹងរដ្ឋប្បវេណីរួមមានប្រាក់ដុល្លា ៥០០ ដុល្លា ប្រាក់រៀល ៧៥ ម៉ឺនរៀល ខ្សែដៃមាសទម្ងន់ ១០ ជី ជញ្ជៀនមាស ១វង់ ទម្ងន់ ១ជី។ ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ ចំនួន ២ លានរៀល។ ការទាមទារលើសពីនេះលើកចោល។

-សាលដីកានេះជំនុំជម្រះថ្ងៃទី ០៥-៤-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២០-៤-២០១២ ដោយសម្រេចសេចក្តី ៖

-ចំពោះមុខជនជាប់ចោទ

-កំបាំងមុខដើមបណ្តឹង

-បើកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកានេះ ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់ដំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី០៣ ខែ....៥.... ឆ្នាំ២០១២

| បានឃើញ | |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |